# ផែនការយុទ្ធសាស្ត្រថវិកា
# របស់ក្រសួងមុខងារសាធារណៈ

# មាតិកា

១. និយមន័យ
២. បេសកកម្មរបស់ក្រសួង
៣. គោលបំណងគោលនយោបាយ
៤. យុទ្ធសាស្ត្រអាទិភាព និងចង្កោមសកម្មភាព
៥. ការរៀបចំថវិកា
៦. ការកំណត់គម្រូវការចំណាយ
៧. ការពិចារណាលើការរៀបចំថវិកាកម្មវិធី ក.ម.ស.
៨.សេចក្តីសន្និដ្ឋាន

# ១. និយមន័យ

- ផែនការយុទ្ធសាស្រ្តថវិកា(BSP)
  - ជាផែនការថវិការយៈពេលមធ្យម(៣ឆ្នាំ) ដែលក្រសួង ស្ថាប័ននិងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំក្នុងដំណាក់កាលទី១ (មេសា-ឧសភា)នៃការរៀបចំថវិកាប្រចាំឆ្នាំនីមួយៗ
  - ផែនការនេះរួមមានការឆ្លុះបញ្ជាំងគោលបំណងគោលនយោបាយ ការកសាងកម្មវិធី/យុទ្ធសាស្រ្តអាទិភាព និងការកំណត់សូចនាករ ដើម្បីរួមចំណែកក្នុងការសម្រេចផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល

# និយមន័យ(៣)

- ផែនការយុទ្ធសាស្ត្រថវិកា ទាមទារការកំណត់ធនធានទាំងថវិកាចរន្ត និងថវិកាមូលធនដែលត្រូវការ និងប្រើប្រាស់សម្រាប់ឆ្នាំថវិកាកំពុងរៀបចំ និងពីរឆ្នាំទៅមុខទៀតដើម្បីសម្រេចគោលបំណងគោលនយោបាយ និងកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន

➢ ចក្ខុវិស័យ

- ជាទស្សនទានទូលំទូលាយមួយដែលបង្ហាញពីបំណងប្រាថ្នារយៈពេលវែង។

- គោលនយោបាយ
  - ជាឧបករណ៍ ឬមធ្យោបាយ ដើម្បីឈានទៅសម្រេចទិសដៅ និងចក្ខុវិស័យដែលបានកំណត់
- គោលបំណង
  - គឺជាការកំណត់ពីបំណង និងពេលវេលាដែលអាចសម្រេចបានទិសដៅគោលនយោបាយដែលបានដាក់ចេញ
- យុទ្ធសាស្ត្រ
  - ជាវិធីសាស្ត្រក្នុងការអនុវត្ត ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយនិងគោលបំណងដែលបានដាក់ចេញ

- ចង្កោមសកម្មភាព
  - ជាបណ្តុំសកម្មភាព( Actions ) ដែលបម្រើឲ្យគោលបំណងនៃអនុកម្មវិធី។
- លទ្ធផលក្នុងឆ្នាំ
  - ជាលទ្ធផលដែលអាចវាស់បានក្នុងឆ្នាំ ក្រោយពីការអនុវត្តកម្មវិធី អនុកម្មវិធី ឬចង្កោមសកម្មភាព។
- លទ្ធផលចុងក្រោយ
  - ជាលទ្ធផលសម្រេចបានពីមួយឆ្នាំទៅមួយឆ្នាំ ក្រោយពីការអនុវត្តបានពេញលេញនូវអនុកម្មវិធី និងកម្មវិធីក្នុងរយៈពេលកំណត់មួយ។

- សូចនាករសមិទ្ធកម្ម
  - ជារង្វាស់លើលទ្ធផលដែលសម្រេចបាន

# ២. បេសកកម្ម ក.ម.ស.

- បេសកកម្មរបស់ក.ម.ស.
  - ដឹកនាំ និងគ្រប់គ្រងវិស័យមុខងារសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍជាតិ ព្រមទាំងការវិវត្តន៍ជាអន្តរជាតិ

# ៣.គោលបំណងគោលនយោបាយ

ក.ម.ស.មានគោលបំណងគោលនយោបាយចំនួនពីរគឺ៖

- គ.ប. ទី១ ៖ កែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ ដែលមានយុទ្ធសាស្រ្តអាទិភាពចំនួន៣គឺ
  - ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ
  - ការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន
  - កែទម្រង់ប្រព័ន្ធបៀវត្ស និងលាភការផ្សេងៗ

- គ.ប.ទី២ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យ មុខងារសាធារណៈ ដែលមានយុទ្ធសាស្ត្រអាទិភាព ចំនួន២គឺ៖
  - ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងមន្ត្រីរាជការ និងការកែលម្អរបៀបគ្រប់គ្រងនិងចាត់ចែងការងារ
  - គាំទ្រនិងសម្របសម្រួលកិច្ចការទូទៅរបស់ក្រសួង និងមន្ទីរក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ

# ៤.យុទ្ធសាស្ត្រអាទិភាពនិងចង្កោមសកម្មភាព

- យុទ្ធសាស្ត្រអាទិភាពទី១៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដែលត្រូវអនុវត្តតាមចង្កោមសកម្មភាពចំនួនពីរគឺ
  - ជម្រុញការអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈការលើកកម្ពស់គណនេយ្យភាពនិងប្រសិទ្ធភាបនៃផ្តល់សេវាសាធារណៈ
  - បង្កើតយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃការគ្រប់គ្រងគុណផល និងជំរុញការងារអធិការកិច្ចតាមក្រសួង ស្ថាប័ន

# យុទ្ធសាស្រ្តអាទិភាពនិងចង្កោមសកម្មភាព (ត)

- យុទ្ធសាស្រ្តអាទិភាពទី២៖ ការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ដែលត្រូវអនុវត្តតាមចង្កោមសកម្មភាពចំនួនពីរគឺ
  - អភិវឌ្ឍសមត្ថភាពរបស់មន្រ្តីរាជការស៊ីវិល
  - ការបណ្តុះបណ្តាលមន្រ្តីរាជការស៊ីវិលតាមរយៈសាលាភូមិន្ទរដ្ឋបាល

# យុទ្ធសាស្ត្រអាទិភាពនិងចង្កោមសកម្មភាព (ត)

- យុទ្ធសាស្ត្រអាទិភាពទី៣ ៖កែទម្រង់ប្រព័ន្ធបៀវត្ស និងលាភការផ្សេងៗ ដែលត្រូវអនុវត្តតាមចង្កោមសកម្មភាពចំនួនមួយគឺ
  - រៀបចំកែទម្រង់ប្រព័ន្ធបៀវត្សឲ្យមានលក្ខណៈសង្គតិភាព សមធម៌ និងគាំទ្រផលិតភាព

# យុទ្ធសាស្ត្រអាទិភាពនិងចង្កោមសកម្មភាព (ត)

- យុទ្ធសាស្ត្រអាទិភាពទី៥៖ គាំទ្រនិងសម្របសម្រួលកិច្ចការទូទៅរបស់ក្រសួង និងមន្ទីរក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ដែលត្រូវអនុវត្តតាមចង្កោមសកម្មភាពចំនួនបីគឺ
  - គាំទ្រនិងសម្របសម្រួលកិច្ចការទូទៅ
  - ការងារផែនការ ហិរញ្ញវត្ថុ ផ្គត់ផ្គង់ និងការងារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
  - ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ (មន្ទីរមុខងារសាធារណៈទាំង២៥ រាជធានី/ខេត្ត

# យុទ្ធសាស្ត្រអាទិភាពនិងចង្កោមសកម្មភាព (៣)

- យុទ្ធសាស្ត្រអាទិភាពទី៤៖ ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងមន្ត្រីរាជការ និងការកែលម្អរបៀបគ្រប់គ្រងនិងចាត់ចែងការងារដែលត្រូវអនុវត្តតាមចង្កោមសកម្មភាពចំនួនបីគឺ
  - ពង្រឹងការត្រួតពិនិត្យរដ្ឋបាល ការគ្រប់គ្រងក្របខ័ណ្ឌ ការងារនីតិកម្ម និងកិច្ចការមុខងារសាធារណៈអាស៊ាន
  - ជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និងកែលម្អការចាត់ចែងការងារ
  - ជំរុញការងារវិសហមជ្ឈការនិងការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ

# ៥. ការរៀបចំថវិកា

- ផ្អែកតាមសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាល
- ការព្យាការណ៍ផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ (កំណើនសេដ្ឋកិច្ចអតិផរណា ផ.ស.ស.(GDP)
- ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយកម្មវិធីគួរផ្អែកលើគោលបំណងគោលនយោបាយនៅក្នុងផែនការយុទ្ធសាស្ត្រថវិកានិងផែនការថវិកាប្រចាំឆ្នាំ

# ៥. ការរៀបចំថវិកា(ត)

- គោលបំណងគោលនយោបាយរបស់ក្រសួង គួរផ្សារភ្ជាប់ទៅនឹងគោលបំណង

  គោលនយោបាយជាតិ:

  – ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP)
  – យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣
  – ផែនការផ្សេងៗរបស់ក្រសួង
  – ក្រសួងមួយ មានគោលបំណងគោលនយោបាយមួយឬយ៉ាងច្រើនពីរ ហើយអាចមានកម្មវិធីយ៉ាងច្រើនបំផុតប្រាំ

# ៦. ការកំណត់តម្រូវការចំណាយ

- ផ្អែកលើយុទ្ធសាស្ត្រអាទិភាព
- ផ្អែកលើចង្កោមសកម្មភាព
- ផ្អែកលើធាតុចូល៖ ថ្លៃចំណាយធាតុចូលចរន្ត Recurrent Inputs : ( 60 61 62 63 64 & 65 ) និង ចំណាយធាតុចូលមូលធន ( Capital Inputs ) ( 20 & 21 )

# ៧.ការពិចារណាលើការរៀបចំផែនការកម្មវិធីរបស់ក្រសួងមុខងារសាធារណៈ

- គោលបំណងគោលនយោបាយទី១៖ កែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ (កម្រិតថ្នាក់ដឹកនាំក្រសួង)
  - កម្មវិធីទី១៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ (អគ្គនាយកដ្ឋានគោលនយោបាយ និងអគ្គាធិការដ្ឋាន)
    - អនុកម្មវិធីទី១៖ ជម្រុញការអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ការលើកកម្ពស់គណនេយ្យភាព និងប្រសិទ្ធិភាពនៃសេវាសាធារណៈ
    - អនុកម្មវិធីទី២៖ បង្កើតយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការគ្រប់គ្រងគុណផល និងជម្រុញការងារអធិការកិច្ចតាមក្រសួង ស្ថាប័ន

- កម្មវិធីទី២៖ ការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន (សាលាភូមិន្ទរដ្ឋបាល និងអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ)
  - អនុកម្មវិធីទី១៖ អភិវឌ្ឍសមត្ថភាពការងាររបស់មន្ត្រីរាជការស៊ីវិល
  - អនុកម្មវិធីទី២៖ ការបណ្តុះបណ្តាលមន្ត្រីរាជការតាមរយៈសាលាភូមិន្ទរដ្ឋបាល
- កម្មវិធីទី៣៖ កែទម្រង់ប្រព័ន្ធបៀវត្សនិងលាភការផ្សេងៗ (ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស)
  - អនុកម្មវិធីទី១៖ រៀបចំកែទម្រង់ប្រព័ន្ធបៀវត្សឲ្យមានលក្ខណៈសង្គតិភាព សមធម៌ និងគាំទ្រផលិតភាព

- **គោលបំណងគោលនយោបាយទី២៖ ការគ្រប់គ្រងនិងអភិវឌ្ឍវិស័យមុខងារសាធារណៈ (កម្រិតថ្នាក់ដឹកនាំក្រសួង)**
  - កម្មវិធីទី១៖ ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងមន្ត្រីរាជការនិងការកែលម្អរបៀបរបបគ្រប់គ្រងនិងចាត់ចែងការងារ (អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ)
    - អនុកម្មវិធីទី១៖ ពង្រឹងការត្រួតពិនិត្យរដ្ឋបាល ការគ្រប់គ្រងក្របខណ្ឌ ការងារនីតិកម្ម
    - អនុកម្មវិធីទី២៖ កិច្ចការមុខងារសាធារណៈអាស៊ាននិងទំនាក់ទំនងអន្តរជាតិ
    - អនុកម្មវិធីទី៣៖ ជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និងកែលម្អការចាត់ចែងការងារ
    - អនុកម្មវិធីទី៤៖ ជម្រុញការងារវិសហមជ្ឈការនិងការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ

- កម្មវិធីទី២៖ គាំទ្រនិងសម្របសម្រួលកិច្ចការទូទៅរបស់ក្រសួង និងមន្ទីរក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ (អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ)
  - អនុកម្មវិធីទី១៖ គាំទ្រនិងសម្របសម្រួលកិច្ចការទូទៅ
  - អនុកម្មវិធីទី២៖ ការងារផែនការ ហិរញ្ញវត្ថុ ផ្គត់ផ្គង់ និងការងារហេដ្ឋារចនាសម្ព័ន្ធ
  - អនុកម្មវិធីទី៣៖ ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ (មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ទាំង២៥)

# សន្និដ្ឋាន

– ក្រសួងបានតម្រង់ទិសទៅរកការអនុវត្តថវិកាកម្មវិធីនៅឆ្នាំ២០១៧
– គោលបំណងគោលនយោបាយមានពីរគឺ
  - កែលម្អ អភិបាលកិច្ចក្នុង រដ្ឋបាលសាធារណៈ
  - ការគ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ

# សន្និដ្ឋាន(ត)

– ដែលនឹងត្រូវអនុវត្តតាមកម្មវិធី/យុទ្ធសាស្ត្រអាទិភាពចំនួន៥គឺ៖
  - ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ
  - ការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន
  - កែទម្រង់ប្រព័ន្ធបៀវត្ស និងលាភការផ្សេងៗ
  - ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងមន្ត្រីរាជការ និងការកែលម្អរបៀបគ្រប់គ្រងនិងចាត់ចែងការងារ
  - គាំទ្រនិងសម្របសម្រួលកិច្ចការទូទៅរបស់ក្រសួង និងមន្ទីរក្នុងក្របខ័ណ្ឌក្រសួងមុខងារសាធារណៈ

# ការពិភាក្សា

- ការកំណត់កម្មវិធី និងគោលបំណងរបស់កម្មវិធីនីមួយៗ
- ការកំណត់អនុកម្មវិធីនិងសកម្មភាព

# សូមអរគុណ!!!